**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

---

សំណុំរឿងរដ្ឋប្បវេណី

**អាងនាមប្រជារាស្ត្រខ្មែរ**

លេខ : ១១១

**តុលាការកំពូល**

ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៥

សាលដីកា

បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៦

លេខ : ៣៤០

ដោយមានសមាសភាពដូចតទៅ :

ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៦

| | | |
|---|---|---|
| ១- ឯកឧត្តម | **ខិត ឧទ្ទី** | ជាប្រធាន |
| ២- លោក | ស៊ិន ឌឹម | ជាចៅក្រម |
| ៣- លោក | យស់ ស្វឿន | ជាចៅក្រម |
| ៤- លោក | ម៉ុង មុន្នីចរិយា | ជាចៅក្រម |
| ៥- លោក | យូរ ឧត្តរា | ជាចៅក្រមរបាយការណ៍ |

ក្រឡាបញ្ជី

លោក **ស៊ិន ភារៈ**

តំណាងមហាអយ្យការ

លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ១៤៧ "ឈ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១៨១ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ រវាង :

-ដើមចោទឈ្មោះ **កាន់ ប៊ុនថា** "ជាចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះ ទីលំនៅសព្វថ្ងៃផ្ទះលេខ៨៨ ផ្លូវ៣៦៩ សង្កាត់ច្បារអំពៅ២ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះកាន់ ញិល "ស" ម្តាយឈ្មោះប៊ុន ខែ "ស" ប្តីឈ្មោះហុង សារ៉ាវង្ស ។

-មានមេធាវី លោក **ឈីវ ថេង**

-ចុងចម្លើយឈ្មោះ **គីម អៀង** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះ ទីលំនៅសព្វថ្ងៃផ្ទះលេខ៩២៧ ផ្លូវ៣៦៧ សង្កាត់ច្បារអំពៅ២ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះវិន លឿង "ស" ម្តាយឈ្មោះឡិប "រ" ប្តីឈ្មោះយូ ប៊ុនធឿន "ស" ។

**<u>កម្មវត្ថុ</u>** : ប្តឹងសុំសិទ្ធិគ្រប់គ្រងដីភូមិ ។

-បានឃើញបណ្ដឹងសាទុក្ខលេខ៤៣៤ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់ឈ្មោះ គីម អៀង ប្ដឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ១៤៧ "ឃ" ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៤ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១១១ ចុះថ្ងៃទី៣១-០៣-២០០៥របស់តុលាការកំពូល ។

-តាមពាក្យបណ្ដឹង ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៣ របស់តាន់ ប៊ុនថា ជាដើមចោទថា: ខ្លួនសុំឱ្យឈ្មោះគីម អៀង គោរពតាមលិខិតផ្ទេរសិទ្ធិគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ចុះថ្ងៃទី២០ ខែសីហាឆ្នាំ២០០១ និងប្ដឹងសុំឱ្យឈ្មោះគីម អៀង ព្រមទាំងក្រុមគ្រួសារ ចុះចេញពីផ្ទះលេខ៥២៧ ដោយមូលហេតុឈ្មោះ តាំង គីមអេង និង យូ ប៊ុនធឿន បានខ្ចីប្រាក់ខ្លួនចំនួន៥.០០០ដុល្លា ដោយបានធ្វើកិច្ចសន្យាផ្ដិតមេដៃ ហើយឈ្មោះគីម អៀង បានផ្ដិតមេដៃដឹងឮដែរ ក្រោយមកអ្នកទាំងបីបានមកខ្ចីលុយខ្លួនចំនួន៥.៧០០ដុល្លា-អាមេរិកថែមទៀត ហើយបានធ្វើលិខិតគ្រប់គ្រង និងប្រើប្រាស់ដីធ្លី(លក់ផ្ទះ) មកឱ្យខ្លួនដោយមានមេភូមិនៅសង្កាត់ដឹងឮផង ។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៥៤២"គ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៣ និងសំណូមពររបស់អ្នកស្រីកាន់ ប៊ុនថា ដើមចោទទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០១ ដែលឈ្មោះតាំង គីមអេង និងឈ្មោះយូ ប៊ុនធឿន ផ្ទេរសិទ្ធិគ្រប់គ្រងកាន់កាប់ និងប្រើប្រាស់ដីផ្ទះលេខ៥២៧ ផ្លូវ៣៦៧ ក្រុម១១ ភូមិកណ្ដាល សង្កាត់ច្បារអំពៅ២ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ អោយទៅឈ្មោះកាន់ ប៊ុនថា ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-អោយអ្នកស្រី គីម អៀង និងក្រុមគ្រួសាររុះរើយកទ្រព្យសម្បត្តិចុះចេញពីដី-ផ្ទះលេខ៥២៧ ផ្លូវ៣៦៧ ក្រុម១១ ភូមិកណ្ដាល សង្កាត់ច្បារអំពៅ២ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ក្នុងរយៈពេល១៥ថ្ងៃ គិតពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ។

៤-អោយអ្នកស្រី គីម អៀង បង់ប្រាក់ប្រដាប់ក្ដី គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្វ៊ីង១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០៛ បូកសរុប៧.០០០៛ ប្រាក់នេះកាត់យកពីប្រាក់៧.០០០៛ ដែលអ្នកស្រី កាន់ ប៊ុនថា បានបង់ទុកជាស្រេច ។

កាលបើហួសបណ្ដឹងឧទ្ធរណ៍ហើយ អោយអ្នកស្រី គីម អៀង សងប្រាក់៧.០០០៛អោយទៅអ្នកស្រី កាន់ ប៊ុនថា វិញ តាមច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដី ។

៥-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្ដី សំរេចបើកផ្លូវប្ដឹងឧទ្ធរណ៍រយៈពេលពីរខែ គិតពីថ្ងៃនេះតទៅ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៥៦"គ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះគីម អៀង ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៥២"គ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូលនៃសាលក្រម ។

-បានឃើញសាលដីការដ្ឋប្បវេណីលេខ៩៧"ឃ" ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះ គីម អៀង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ៥២"គ" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ គឺពន្ធចុះបញ្ជីក្តីនិងពន្ធហ្វឹងចំនួន២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០៛ ចំណាយលើការប្រគល់ដីកាកោះចំនួន៥.០០០៛ និងអាជ្ញាធរតុលាការចំនួន៥.០០០៛ សរុប១៣.០០០រៀល

៤-សាលដីកានេះជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៤ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងទាស់លេខ៩៨ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៤ របស់ឈ្មោះគីម អៀង ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ៩៧"ឃ" ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសាលដីការដ្ឋប្បវេណីលេខ១៤៧ "ឃ" ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៤ របស់ឈ្មោះ គីម អៀង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ៩៧"ឃ"ចុះថ្ងៃទី២៧ ខែកក្កដាឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៤-សាលដីកានេះជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ ចំពោះមុខគូក្តី និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៤ ចំពោះមុខគូក្តី ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៤៣៤ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់ឈ្មោះ គីម អៀង ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ១៤៧ "ឃ" ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៤ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៥ របស់ឈ្មោះ គីម អៀង ។

-បានឃើញសារណាតប ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៥ របស់ឈ្មោះ កាន់ ប៊ុនថា ។

-បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : រឿងនេះគឺជារឿងប្ដឹងសុំសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

-បានស្ដាប់ចម្លើយរបស់ឈ្មោះ គីម អៀង នៅពេលសវនាការថា : រឿងលុយនេះម្ដាយក្មេកខ្លួនឈ្មោះតាំង គីមអេង គាត់ជាអ្នកខ្ចីចំនួន៥.០០០ដុល្លាអាមេរិក ពីឈ្មោះកាន់ ប៊ុនថា ដើម្បីយកមកមើលជម្ងឺប្ដីរបស់ខ្លួនឈ្មោះយូ ប៊ុនធឿន ដោយអោយការប្រាក់ក្នុងមួយខែ២២៥ដុល្លាអាមេរិក ។ ក្រោយមកប្ដីខ្លួនគាត់បានស្លាប់ ហើយបន្ទាប់មករយៈពេល៦ខែទៀត ម្ដាយក្មេកខ្លួនគាត់បានស្លាប់ទៀត ។ ខ្លួនបានសងប្រាក់១.០០០ដុល្លាអាមេរិកអោយអ្នកស្រីកាន់ ប៊ុនថា ខ្លួនមិនបានធ្វើសំបុត្រស្នាមទេ ។ ខ្លួនសូមទទួលស្គាល់តែប្រាក់៥.០០០ដុល្លាអាមេរិកទេ ក្រៅពីនេះខ្លួនមិនបានខ្ចីទេ ។

-បានស្ដាប់ចម្លើយរបស់ឈ្មោះ កាន់ ប៊ុនថា នៅពេលសវនាការថា : ដើមឡើយឈ្មោះតាំង គីម-អេង និងឈ្មោះយូ ប៊ុនធឿន ជាប្ដីឈ្មោះគីម អៀង បានខ្ចីប្រាក់ពីខ្លួនចំនួន៥.០០០ដុល្លាអាមេរិក ដោយសន្យាឱ្យការប្រាក់២២៥ដុល្លាអាមេរិកក្នុងមួយខែ និងបានធ្វើកិច្ចសន្យាផ្ដិតមេដៃ ហើយឈ្មោះគីម អៀង ក៏បានផ្ដិតមេដៃដឹងលឺលើកិច្ចសន្យានេះដែរ ។ ក្រោយមកទៀតអ្នកទាំងបីបានមកខ្ចីលុយពីខ្លួនចំនួន៥.៧០០ដុល្លាអាមេរិកថែមទៀត ដោយបានធ្វើលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី "លក់ផ្ទះ" មកឱ្យខ្លួនព្រមទាំងមានមេភូមិ សង្កាត់ដឹងលឺទៀតផង ។ ពេលនោះអ្នកទាំងបីនាក់មិនចុះចេញភ្លាម១នោះទេ ហើយបានសុំខ្លួនស្នាក់នៅជាបណ្ដោះអាសន្នរង់ចាំរកផ្ទះបានទើបចុះចេញ ។ លុះក្រោយមកទៀតឈ្មោះតាំង គីមអេង និងឈ្មោះយូ ប៊ុនធឿន ជាប្ដីឈ្មោះគីម អៀង បានស្លាប់បាត់ ហើយនៅតែប្រពន្ធឈ្មោះគីម អៀងកំពុងរស់នៅ និងគ្រប់គ្រងផ្ទះ និងដីដែលបានលក់ឱ្យខ្លួនរួចហើយ ឈ្មោះគីម អៀង មិនព្រមចុះចេញទេ ។ ខ្លួនសំណូមពរសូមតំកល់សាលដីកាសាលាឧទ្ធរណ៍ទាំងមូល ។

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់លោក ឈើរ ថេង ជាមេធាវីការពារអោយដើមចោទ នៅពេលសវនាការថា : ការពាក់ពាន់ខ្ចី និងចងការប្រាក់ចំនួន៥.០០០ដុល្លាអាមេរិកក្នុង១ខែ ការប្រាក់២២៥ដុល្លាអាមេរិក ឃើញការប្រាក់ខ្ពស់ពេក គាត់បានយកលុយបន្ថែមពីកូនក្ដីខ្លួនចំនួន៥.៧០០ដុល្លាអាមេរិកទៀតព្រមទាំងបានធ្វើលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី "គឺការលក់ផ្ទះមកឱ្យកូនក្ដីខ្លួន" ។ ពេលនោះដែរអ្នកទាំង៣ មិនបានប្រគល់ផ្ទះមកអោយកូនក្ដីខ្លួនភ្លាម១ទេហើយគាត់ថែមទាំងបានស្នាក់នៅជាបណ្ដោះអាសន្ន ។ មកដល់ពេលនេះឈ្មោះគីម អៀងមិនព្រមចុះចេញពីផ្ទះនិងដីនេះឡើយ ទើបបានជាកូនក្ដីខ្លួនប្ដឹងទាមទារដល់សព្វថ្ងៃនេះ ។ ខ្លួនសំណូមពរមេត្តាតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ។ និងសុំឱ្យឈ្មោះគីម អៀង ចុះចេញពីផ្ទះរបស់កូនក្ដីខ្លួន ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និង សេចក្តីសន្និដ្ឋានមេធាវីការពាររបស់ដើមចោទ .

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤៣៤ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៤របស់ឈ្មោះគឹម អៀង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ក៏ដូចជាតុលាការក្រុងភ្នំពេញដែរ ដែលសម្រេចអោយចុងចម្លើយចុះចេញពីផ្ទះលេខ៥២៧ ផ្លូវ៣៦៧ សង្កាត់ច្បារអំពៅ ក្រុងភ្នំពេញ ដោយសំអាងលើកិច្ចសន្យាផ្ទេរសិទ្ធិគ្រប់គ្រងដី ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០១នោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា តាមកិច្ចសន្យាចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០១ គឺជាកិច្ចសន្យាខ្ចីចង់ការប្រាក់ចំនួន៥.០០០ដុល្លា ។

-យល់ឃើញថា ការដែលដើមចោទបានអះអាងថា បានផ្តល់ប្រាក់បន្ថែមចំនួន៥.៧០០ដុល្លា ដើម្បីបង្គ្រប់ការទិញផ្ទះខាងលើនេះ ពុំមានភស្តុតាងអ្វីជាឯកសារសម្រាប់ដាក់ជូនតុលាការពិចារណាឡើយ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៤៧ "ឈ" ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទម្រង់ និងគតិច្បាប់ ។

## ហេតុដូច្នេះ

## *វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី :*

១-ទទួលបណ្តឹងសាទុក្ខលេខ៤៣៤ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់ឈ្មោះ គឹម អៀង ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ១៤៧"ឈ" ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ១១១ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៥របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលដើមចោទបានបង់នៅតុលាការកំពូលចំនួន១៩.០០០រៀល គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊្នឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

៥-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៦ ។